# សេចក្តីប្រកាសព័ត៌មាន

## ប្រតិភូជាន់ខ្ពស់កម្ពុជាអំពាវនាវឲ្យ
## ប្រទេសសិង្ហបូរីចូលរួមក្នុងអនុសញ្ញាប្រឆាំងគ្រាប់មីន

*សឹង្ហបូរី ថ្ងៃទី ៤ តុលា ២០១១* - គណៈប្រតិភូកម្ពុជាមួយក្រុមដែលដឹកនាំដោយ ឯកឧត្តម ប្រាក់ សុខុន រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី និងជាប្រធានតែងតាំងនៃកិច្ចប្រជុំរដ្ឋភាគីលើកទី១១ (11MSP) នៃអនុសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស បានមកដល់ប្រទេសសឹង្ហបូរីថ្ងៃនេះដើម្បីលើកទឹកចិត្តដល់អាជ្ញាធរសឹង្ហបូរីក្នុងការជំរុញការចូលរួមក្នុងចលនាអន្តរជាតិដើម្បីលុបបំបាត់គ្រាប់មីនប្រឆាំងមនុស្ស។

នៅក្នុងជំនួបប្រជុំជាមួយ ឯ.ឧ. ខេ. សាន់មូហ្គាម (K. Shanmugam) រដ្ឋមន្ត្រីការបរទេសនិង ឯ.ឧ. ងឹ អេងហេន (Ng Eng Hen) រដ្ឋមន្ត្រីការពារជាតិសឹង្ហបូរី ឯ.ឧ. ប្រាក់ សុខុន បានរំលឹកថា នៅឯជំនួបថ្នាក់ដឹកនាំនៃកិច្ចប្រជុំកំពូលអាស៊ាន នាទីក្រុងហ្សាកាតា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសំដែងនូវក្តីសង្ឃឹមថា រដ្ឋសមាជិកអាស៊ាន នឹងបញ្ជូនគណៈប្រតិភូជាន់ខ្ពស់របស់ខ្លួនដើម្បីចូលរួមក្នុងកិច្ចប្រជុំរដ្ឋភាគីលើកទី១១ ដែលនឹងប្រព្រឹត្តទៅនៅប្រទេសកម្ពុជានាចុងឆ្នាំនេះ។

"ដោយកិច្ចប្រជុំរដ្ឋភាគីលើកទី១១ នឹងប្រព្រឹត្តទៅនៅតំបន់អាស៊ីអគ្នេយ៍ ជាតំបន់មួយដែលប្រទេសជាច្រើនបានទទួលរងឥទ្ធិពលនៃជំលោះសង្គ្រាមពីអតីតកាល កិច្ចប្រជុំដ៏មានសារៈប្រយោជន៍នេះនឹងផ្តល់នូវឱកាសមួយសម្រាប់រដ្ឋសមាជិកអាស៊ាន ដើម្បីបង្ហាញពីចំណងសាមគ្គីភាព ក្នុងការដោះស្រាយបញ្ហាប្រឈមទាំងនេះ" ។ យើងទាំងអស់គ្នា គឺជាតំណាងនៃភាពចំរុះបែបនៃចលនានេះ ពោលមានទាំងរដ្ឋដែលរងផលប៉ះពាល់ដោយគ្រាប់មីន រដ្ឋដែលរួចផុតពីផលប៉ះពាល់ដោយគ្រាប់មីន ក៏ដូចជារដ្ឋដែលមានកម្រិតអភិវឌ្ឍន៍ខុសៗគ្នា។ ក្នុងនាមជាគ្រួសារអាស៊ាន យើងអាចពួតដៃគ្នាដោយសារការតាំងចិត្ត រួបរួមគ្នាក្នុងការបន្តកិច្ចខិតខំប្រឹងប្រែងនេះ។" យោងតាមប្រសាសន៍របស់ ឯកឧត្តម ប្រាក់ សុខុន។

ឯកឧត្តម ប្រាក់ សុខុន បានសំដែងនូវក្តីសង្ឃឹមផងដែរថា ប្រទេសសឹង្ហបូរី នឹងចូលរួមក្នុងអនុសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស ឬ *អនុសញ្ញាអូតាវ៉ា* នៅថ្ងៃណាមួយ។

"ការចូលរួមក្នុងអនុសញ្ញា ពីរដ្ឋសមាជិកអាស៊ីអគ្នេយ៍មួយទៀតនឹងរឹតតែជួយពង្រឹងនូវចលនាអន្តរជាតិដើម្បីលុបបំបាត់ចោលនូវគ្រាប់មីនប្រឆាំងមនុស្ស" យោងតាមប្រសាសន៍របស់ ឯកឧត្តម ប្រាក់ សុខុន។

ថ្វីបើប្រទេសសឹង្ហបូរីមិនមែនជាសមាជិកនៃអនុសញ្ញា តែប្រទេសនេះបានដាក់ឱសានវាទការនាំចេញគ្រាប់មីនប្រឆាំងមនុស្សតាំងពីឆ្នាំ១៩៩៨មកម្ល៉េះ។ ប្រទេសនេះក៏បានបោះឆ្នោតជាបន្តបន្ទាប់គាំទ្រសេចក្តីសម្រេចមហាសន្និបាតអង្គការសហប្រជាជាតិក្នុងការធ្វើសកលភាវូបនីយកម្មនិងការអនុវត្តន៍អនុសញ្ញានេះ និងបានចូលរួម

**AP Mine Ban Convention Implementation Support Unit**
GICHD | 7bis, avenue de la Paix | P.O. Box 1300 | 1211 Geneva 1 | Switzerland | t. + 41 (0)22 906 16 38
f. + 41 (0)22 906 16 90 | isu@apminebanconvention.org | **www.apminebanconvention.org**

កិច្ចប្រជុំកំពូលកាតាហេណាក្នុងឆ្នាំ ២០០៩ ស្តីពីពិភពលោកគ្មានគ្រាប់មីន (Cartagena Summit on a Mine-Free World) ដែលបានរៀបចំឡើងនៅប្រទេសកូឡុំប៊ី។

ឯកឧត្តម ប្រាក់ សុខុន បានចំណាយពេលក្នុងឆ្នាំនៃការត្រៀមរៀបចំកិច្ចប្រជុំរដ្ឋភាគីលើកទី១១ យ៉ាងសកម្មដើម្បីលើកកម្ពស់អនុសញ្ញានេះនៅក្នុងតំបន់អាស៊ីអគ្នេយ៍។ ក្នុងខែសីហាកន្លងទៅនេះ ឯ.ឧ. រដ្ឋមន្ត្រីបានដឹកនាំគណៈប្រតិភូទៅទីក្រុងហាណូយ ដើម្បីជួបជាមួយថ្នាក់ដឹកនាំវៀតណាមពីបញ្ហាចូលរួមជាសមាជិកភាពនៃអនុសញ្ញា។ ក្នុងខែកញ្ញា កម្ពុជាបានរៀបចំសិក្ខាសាលាតំបន់មួយស្តីពី ការបាត់បង់នៃផ្នែកមនុស្សដោយសារគ្រាប់មីនប្រឆាំងមនុស្ស ដែលមានការចូលរួមពីប្រទេសក្នុងតំបន់អាស៊ីចំនួន១១ប្រទេស។

កិច្ចប្រជុំរដ្ឋភាគីលើកទី១១ នឹងមានវត្តមានគណៈប្រតិភូជាង១០០០នាក់ តំណាងឲរដ្ឋជាង១០០ អញ្ជើញចូលរួមនៅរាជធានីភ្នំពេញនៃកម្ពុជា ចាប់ពីថ្ងៃទី ២៧ វិច្ឆិកា រហូតដល់ថ្ងៃទី ២ ធ្នូ ២០១១។ ជាមួយនឹងការជួបប្រជុំដែលមានទ្រង់ទ្រាយធំ ប្រារព្ធធ្វើនៅលើទឹកដីមួយដែលនៅរងទទួលផលប៉ះពាល់មីនច្រើនជាងគេ ពិភពលោកទាំងមូលនឹងបានរំលឹកឡើងវិញនូវសោកនាដកម្មមនុស្សជាតិដោយសារគ្រាប់មីន។

## អនុសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្ស

អនុសញ្ញាហាមប្រាមការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្សត្រូវបានអនុម័តនៅទីក្រុងអូស្លូ ក្នុងឆ្នាំ១៩៩៧ ដោយបើកឲ្យចុះហត្ថលេខានៅទីក្រុងអូតាវ៉ា នៅឆ្នាំដដែល ហើយចូលជាធរមានក្នុង ឆ្នាំ១៩៩៩។

មកដល់សព្វថ្ងៃនេះ មានរដ្ឋចំនួន ១៥៧ ជារដ្ឋភាគីនៃអនុសញ្ញានេះ។ រដ្ឋចំនួន ១៥៣ លែងមានស្តុកនូវគ្រាប់មីននៅក្នុងប្រទេសខ្លួនទៀតហើយ។ ប្រទេសដែលទើបតែបានចូលជាសមាជិកនាពេលថ្មីៗនេះគឺប្រទេសទូវ៉ាលូ កាលពីថ្ងៃទី ១៣ កញ្ញា ២០១១ ដែលសឹងតែធ្វើឲតំបន់ប៉ាស៊ីហ្វិកទាំងមូលជាតំបន់ ដែលជាភាគីនៃអនុសញ្ញាទាំងស្រុង។

គ្រាប់មីនជាង ៤៤លានគ្រាប់ត្រូវបានកំទេចចោលដោយរដ្ឋភាគី។ រដ្ឋចំនួន ៣៤ក្នុងចំណោម ៥០រដ្ឋ ដែលធ្លាប់ជារដ្ឋផលិតនូវគ្រាប់មីនប្រឆាំងមនុស្ស ត្រូវបានជាប់កាតព្វកិច្ចហាមប្រាមលែងឲផលិតដោយសារអនុសញ្ញា។ រដ្ឋមិនមែនជាភាគីស្ទើរតែទាំងអស់ផ្សេងទៀតបានដាក់ឱសានវាទការផលិត និង ផ្ទេរគ្រាប់មីនផងដែរ។

ការបោសសម្អាតមីនបានរំដោះនូវ ផ្ទៃដីរាប់លានម៉ែត្រក្រឡាដែលពីមុនជាដីរងគ្រោះថ្នាក់ដោយសារគ្រាប់មីនសម្រាប់ប្រើប្រាស់ជាសកម្មភាពមនុស្សធម៌ទូទៅ។

សម្រាប់កិច្ចសម្ភាសន៍នានា ឬ ព័ត៌មានលំអិតឯទៀតនៃអនុសញ្ញាសូមផ្ញើអ៊ីម៉ែល: ISU@APMineBanConvention.org ឬទាក់ទង Ms. Laila Rodriguez ទូរស័ព្ទលេខ + 41 (0) 22 906 1656 សូមភ្ជាប់បណ្តាញសម្រាប់កិច្ចប្រជុំតាមរយៈ គេហទំព័រ Facebook, Flickr or Twitter.